ព្រះរាជបណ្ណាល័យកម្ពុជា

# កម្ពុជសុរិយា

## សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគម្រប់ពីរ

លេខ ១០

ក្រុងភ្នំពេញ

រោងពុម្ពរាជការ ផ្លូវវែរណើម៉ុង

គ្រិ. ឆ្នាំ ១៩២៨

ពុ. ស. ២៤៧១

អ្នកទទួលខុសត្រូវ ជុំ-មៅ

# បញ្ជីរឿង


ទំព័រ

១-ប្រវត្តិព្រះពុទ្ធរូបពុទ្ធ សាស្ត្រាចារ្យ សេដេស រៀបរៀងជាភាសាសៀម ព្រះស្នេហាសាទេព បណ្ឌិតនៅព្រះរាជបណ្ណាល័យ ប្រែជាភាសាខ្មែរ ៣០៩

២- អំពីលំនាំដើមហេតុ នៃការដែលបានស្គាល់ប្រាសាទអង្គរ លោកវិគទ័រ-គោលូបែហ្វ អគ្គលេខាធិការ នៅសាលាបារាំងសែសនាចុងបូព៌ាប្រ-ទេស អធិប្បាយ ក្រមការ ជុំ-មៅ ប្រែចេញជាភាសាខ្មែរ . . . ៣២៨

៣- គតិលោក ឬ ច្បាប់ទូន្មានខ្លួន ឧកញ៉ាសុត្តន្តប្រីជាឥន្ទ រៀបរៀង (ត)
(អត្ថបទនេះ មិនមានចុះផ្សាយទេ ព្រោះមានបោះជាសៀវភៅហើយ)

៤- កោសជ ឬ សេចក្តីទុំលប្រអូសពាក្យកាព្យរបស់ ចៅ ជ. គឹមហាក់ ធ្វើរាជការនៅក្នុងមន្ទីរប៉ុស្តិ៍ខ្សែលួសក្រុងភ្នំពេញ រៀបរៀង . . . . ៣៥០

៥- សេចក្តីរាយការណ៍អំពីអ្នកធំណាងខេត្តកំពត នាំប្រាក់ចំនួន ១០០០៛ មកជូនព្រះរាជបណ្ណាល័យកម្ពុជា ក្រមការ ជុំ-មៅ ធ្វើរាជការក្នុងព្រះរាជ-បណ្ណាល័យ អធិប្បាយ . . . . . . . ៣៥៩

# កោសផ

គឺ សេចក្តីខ្ជិលច្រអូស

## ពាក្យកាព្យរបស់ ថី ឆ. គឹមហាក់ ធ្វើរាជការនៅមន្ទីរ

ប៉ុស្តិ៍ខ្សែលួស ក្រុងភ្នំពេញ រៀបរៀង

---

## កោសផ

កោសផជាភាសាបាលី ប្រែតាមសម្តីខ្មែរខ្ជិល

គឺខ្ជិលច្រអូសក្នុងកាយពល គ្មានគិតរវល់ពីការងារ ។
មុននឹងបរិយាយស្រាយរឿងនេះ ខ្ញុំសូមគោរពក្នុងទំយា
រំលឹកដឹងគុណព្រះពុទ្ធា ធម្មាសង្ឃាជូនពេកក្រៃ ។
រួចខ្ញុំសូមថ្លែងចែងអធិប្បាយ កែស្រាយការណ៍តាមដោយនិស្ស័យ
ប្រាជ្ញាខ្ញុំខ្លីតិចក្រៃឧបមេយ្យ ដូចពេជ្រពុំទាន់កាប់រង្សី ។
សូមពួកបណ្ឌិតត្រិះត្រាតាម ខមាទោសអស់សម្តី
ដែលខ្ញុំពោលហើយពុំគប្បី សេចក្តីខុសឆ្គងនឹងពាក្យពិត ។
សព្វលោកត្រូវដឹងប្រឹងបង្ការ កុំឲ្យបាបណាធ្លាមកជិត
ត្រូវចាំសង្កេតមុខហេតុពិត ត្រូវប្រើគំនិតគិតការល្អ ។
ដូចជាគ្រួចសេចក្តីខ្ជិល ក្រាលដោយមន្ទិលអធិករណ៍
ជនកបកេជៈកបៈបវរ គាំងរះយុទ្ធកុំឲ្យបៀត ។

បើទំគ្រែសែតបណ្ដែតចិត្ត ខ្ជិលចូលមកជិតកែសិតសៀត
ទុក្ខាកើនផ្ទួនជួនមកទៀត ទុកស៊ើរទ្វាតឃ្លាតពីប្រាណ ។
ខ្ជិលនាំខូចខាតច្រើនពន្លឹក មហាសន្ធឹកគុណពុំបាន
ផងាខុផងកុំកប់គាន ទើបបានឆ្ងាយថ្កានពីសប្បលក្ខណ៍ ។
ខ្ជិលធ្វើការងារគ្មានផនផាន ខ្ជិលពុំគិតរៀនគ្មានយសសក្តិ
ខ្ជិលគោរពតាតសែស្រស: ខ្ជិលស្ញើគ្រព្រះពុទ្ធគ្មានចេស្ដា ៗ
ខ្ជិលដកដង្ហើមប្រាសដំរៃ ខ្ជិលគិតពុំបានថ្លាបញ្ញា
ខ្ជិលនិយាយពុំចេះកំហារ ខ្ជិលដើរយាត្រាទុំនពុំមាន ៗ
ខ្ជិលស្ដាប់សត្វស្លូវប្រែជាធ្ងន់ ខ្ជិលចង់គង់តែចំណីមានបាន
ខ្ជិលធ្វើបុណ្យមានគង់ក្រប្រាណ ខ្ជិលរកកំសាន្តមានសប្បាយ ៗ
ខ្ជិលសូត្ររៀនធម៌ធ្លាក់នរក ខ្ជិលលក់ទំនិញគ្មានលុយចាយ
ខ្ជិលដូតតង្ហាគង់ក្រហាយ ខ្ជិលសំអាតកាយគ្មានកុនល្អ ៗ
ខ្ជិលថែរក្សាពុំបិតថេរ ខ្ជិលសរសេរពុំចេះអក្សរ
ខ្ជិលពុំចង់មានចំណីបានក្រ ខ្ជិលល្អគង់តែបានអប្រិយ ៗ
ខ្ជិលមើលឃ្លូរទៅគង់ពិលទ្វាក់ ខ្ជិលថ្នាក់ថ្នមថែកក្ដីចេតិ
ខ្ជិលពុំការពារគ្មានស្មារតី ខ្ជិលរកវត្ថុគ្មានដំណក់ ៗ
ខ្ជិលរៀនក្រមច្បាប់គ្រូផ្ដន្ទា ខ្ជិលរកទ្រព្យាគង់កំសត់
ខ្ជិលរៀនគនគាំចេះកត់ ខ្ជិលប្រកគង់គាត់ផលមិនមា-ន ៗ

ខ្ជិលរៀនវិន័យត្រូវតាមក្តិ ខ្ជិលស្អាតធ្វើម្តេចនឹងដូចប្រាណ
ខ្ជិលបោសផ្ទះពុំស្អាតឋាន ខ្ជិលព្រានធ្វើម្តេចរស់ខ្លួន ។
ខ្ជិលចងធ្វើម្តេចនឹងបានជាប់ ខ្ជិលរាប់ធ្វើម្តេចដឹងចំនួន
ខ្ជិលធ្វើមេត្តាឆ្ងាយក្តីស្ងួន ខ្ជិលកួនធ្វើម្តេចនឹងបានបាក់ ។
ខ្ជិលហៅធ្វើម្តេចនឹងស្គាល់នាម ខ្ជិលស្ងៀមធ្វើម្តេចបានក្តីស្ងាត់
ខ្ជិលដេញធ្វើម្តេចនឹងប្រាក់ភ្ជាក់ ខ្ជិលណាត់ធ្វើម្តេចត្រូវវេលា ។
ខ្ជិលលាងធ្វើម្តេចនឹងបានជ្រះ ខ្ជិលធ្វើការហាសភាគភាលា
ខ្ជិលរក្សាសីលកើតវេរ ខ្ជិលចារធ្វើម្តេចគេនឹងសង់ ។
ខ្ជិលឲ្យធ្វើម្តេចគេនឹងអរ ខ្ជិលកំចិញភាគទ្រព្យផង
ខ្ជិលចរចាល្អនាំសៅហ្មង ខ្ជិលចាំងម្តេចនឹងដូចប្រាថ្នា ។
ខ្ជិលទន្ទេញធ្វើម្តេចបានចាំ ខ្ជិលដាំធ្វើម្តេចបានផ្លែផ្កា
ខ្ជិលភាក់ធ្វើម្តេចបានជ្រះថ្លា ខ្ជិលស្អប់តណ្ហាទៅអបាយ ។
ជនអើយមើលចុះខ្ជិលទ្រមក់ នាំកើតកលយុគផងទាំងឡាយ
តែងមករួមគេជិតកិតកាយ នាំឲ្យអន្តរាយច្រើនពេកក្តាត់ ។
បានឃើញរបស់ស្រស់សោភា អស់ទាំងទ្រព្យសឹងសោត
វិនាសសាបសូន្យសណ្ឋានភ្លាក់ ដូចថ្នល់ចបាក់គ្មានគត្តា ។
កុំដែលកណ្តែកក្រៃសែកឡើង កុំដែលបានថ្កើងមួយវេលា
រមែងស្លូចកួចដូចចង្ក្រា រះក្ទុំទេវនាកាលចក្ក ។

ជនខ្ជិលក្តីក្រកើតមកដល់ ក្លាយខ្វល់ចិត្តជ្រួលច្រួលអន់ថាក់
ហាក់ដូចលំពែងស្រួចដាក់ មកចាក់ត្រូវចំដើមទ្រូង ។
ហើយដើរលួចប្លន់សន្សំធន ធ្វើបាបមហាជនច្រើនគ្រៀវក្រា
ធ្វើចញ្ចោកគ្នានគេ ខ្លះអត់អាហារស្លាប់ក្នុងព្រៃ ។
មានខ្លះធ្វើជាស្បមយាចក សូមទានលួចឆក់ផងដៃ
ពុំមានអៀនក្រែងគេ ពុំមានគិតភ័យខ្លាចចងការ ។
ខ្លួនកម្លាំងពេញកាយពល ពុំចេះទប់ទល់លៀងដឹក
បានថ្ងៃយាមមួយស្ទួយដាក់ស្មា ដើរសូមអាហារគេគាស្រ័យ ។
ធ្វើថូកយ៉ាងនេះពេញជាថោក ចាញ់ចុកក្អែកបក្សីថ្លៃ
នាំខូចពូជពង្សវង្សាសាយ ពេញជាចង្រៃក្នុងលោកា ។
ត្រកូលណាមួយមានកូនខ្ជិល វង្សនោះមន្ទិលពុំជ្រះថ្លា
ដូចជាព្រះចន្ទក្នុងរាត្រា រាហ៊ូយក្បាមហាសម្បើម ។
គ្រឿងលានជិតខាងគេនិន្ទា គេប្រជុំគ្នានិយាយដើម
ជាពូជនេះពេញជាពុំឆ្នើម ដូចទឹកសន្សើមដាច់វិនាស ។
មនុស្សខ្ជិលតែងធ្វើឲ្យផ្ដៅ គាប់ខនពាលាពុំទោស
ដូចផ្លែឈើដែលជាប់គ្រឿងប្រាក់មាស នាំកើតទុក្ខសង្រេចទិហាន ។
ខនរនោះឯងដូចជាតា គ្មានកូននោះណាពុំក្តុំជាន
ប៉ុន្តែប្រទៃពីកបកាន ដូចព្រះសុរិយាខាតចន់ស្មើ ។

ហាសនាមប្រុនក្មួនស្រុកនោះ　　កុំបានមានឈ្មោះឆើតសារ
ចាបចន់អន់អួនសួនឲ្យឆាប់ទ្រី　　ដូចនារីកាកីរាតលោកា ។
ទុំប្អូនជាស់កៀនក្រោនកុលបុត្រ　　ដ៏វិសេសសុខុមជ័យ
ត្រូវទំសម្លាប់កាលជា　　ដោយវិរិយាគឺឧស្សាហ៍ ។
ត្រូវមានស្នេហាការដែលធ្វើ　　ត្រូវទំនើតើរៀនចេះចនា
ឲ្យបានតាមនេតកើតផល　　បីដូចមាតាស៊ើត្រូវបុត្រា ។
មិនត្រូវខ្ជិលខ្ជាជាខ្សោយហត់　　ចិត្តត្រូវសង្កត់កល់វេលា
ខិតខំរៀនសូត្រតាមមាគ៌ា　　ដែលប្រាជ្ញនានាបានត្រួចហើយ ។
ត្រជាក់ឬក្តៅក្តីណា　　ត្រូវប្រឹងធ្វើការកុំឲ្យស្បើយ
ទំឲ្យបានផលយល់ការក្រោយ　　ទើបបានក្តីល្ហែយក្នុងកាយា ។
ចម្ងាតំបុប្ផាក្តុឡាប　　កែនក្រោយលូតចេញពិចត្រា
ដូចជាវក្តីថ្ងៃថ្លៃ　　កើតពីទុក្ខកល់ទំរាំ ។
សុខកែនកើតក្រោយទុក្ខជាទិច្ច　　ចេស្តុខសូឲ្យលិចកើតកិយា
គួរកុលបុត្រត្រូវអស្ចា　　កេះគិតពាក្យនេះណា ។
គិតទៅឧទ៍យល់ស្គាល់តម្លៃ　　សុខប្រសើរក្រៃជានិទុក្ខា
បើចង់បានសុខតោនឧស្សាហ៍　　រៀនសូត្រធ្វើការរបរចាំនឲ្យយ ។
មិនត្រូវខ្ជិលដេកត្រេកក្នុងខ្ជិល　　ត្រូវខេះមើលមើលឆាយអាយ
យល់ការកក់ប្រាំទៅវែងឆ្ងាយ　　ទើបបានសប្បាយកាយកិរិយា ។

គ្រូមានពាក្យយាមឲ្យណាស់សា | ខុចមាជួបសក្ការធ្វើទ្រង់
កណ្ដៀរតូចប្រាណមិនបានធំ | ពាំដីមកផ្គុំធ្វើគ្រឹហា ។
តូច ៗ តិច ៗ ប៉ុចផ្ដិ | ជាដំបូកធំខ្ពស់មហិមា
កើតពាក្យយាមតាមពណ៌នា | គួរជនកុំកំយ៉ាងញ៉ឹង ។
មិនត្រូវគិតណាយស្ដាយកម្លាំង | តោងចេះតតាំងរកទីពឹង
រិះរកថ្លៃជាធុនធឹង | តោងចេះថ្លឹងប្រើប្រាជ្ញា ។
តោងយល់ថាថ្លៃលោកិយ៍ | លោកុត្តរក្ដីធំណាស់សា
កម្រិះចេះគិតចេះសូត្រថា | ចំណេះគាថាឥតនរណាស្មើ ។
គិតថែមដូចនេះប្រែហាសសល់ | ខ្ទីលខឹងមកផ្ដល់ខនដំណើរ
ខ្លួចកិច្ចរៀនកម្រិះប្រសើរ | ខានដើរទៅកាន់គូមិស្រុក ។
គំនិតគិតនេះដូចកន្លប | ពួនអែបក្ទន់ទឹកអណ្ដូងណា
សម្គាល់យល់ទីនៃគាថា | គ្មានរលផលសាណាស្មើបាន ។
ប្រសិនប្រសព្វឃើញសម្រេច | គង់តែខ្ទង់ស្ដុកមិនខាន
កន្ទិបតង់គិតកិតភ្ញាក់ប្រាណ | មើលឆ្ងាយចំហាំនរបស់ខ្លួន ។
បើកន្ទិបឆ្លាតមានប្រាជ្ញា | គង់ទឹងប្រាជ្ញាយ៉ាងសមសួន
ចង់បាននាទីដែលធំធួន | បានខ្លួនហៃលលេងជាសុខុម ។
ដូចជាកុលបុត្រប្រកបលក្ខណ៍ | ទំនិតស្មួនស្ទាក់ប្រមូលផ្ដុំ
ប្រាជាតេរៀនថ្លៃធំ | ត្រែសែកត្រេស្ទុំតាមវេណី ។

ទំនៀមគុំឈប់ទំសំក

កាន់ពីព្រលឹមទល់ព្រលប់
ទំយាក់គ្មានសម្រាន្ត ។

ពិនិត្យធម៌គាថាក្នុងគម្ពីរ
ដែលព្រះពុទ្ធទុកឲ្យគ្រប់ប្រាណ

ច្រើនរៀនវិន័យបច្ច័យសុខ
ដឹងអស់លាក់ហានទោសគាថា ។

ស្គាល់ដឹងអាបត្តិតាំងពុំគ្មាន
ឬនៅក្មេងណាស់ក្រណាខា

មិនចេះពោលថាគាថាចាស់
នាំឲ្យវេទនាលំបាកកាយ ។

មិនគួរទំនៀមវិន័យា
ក្រយ៉ាងសន្ធៅពៅវែងឆ្ងាយ

ពីព្រោះវិន័យច្រើនហើយជ្រៅ
ខុសកាយក្រសោបខុចគីរ ។

ហត្ថាទ្វីសល់កុំខ្វល់ឆ្ងាយ
ហៅថាពុំចេះល្ងង់ពេញទី

កុលបុត្រណាពោលតាំងពាលនេះ
ជាទីគួរគិតពិចារណា ។

មើលសត្វស្រមោចលើថ្ងៃថតី
ប្រើនទំរបល់តាំងអាហារ

ស្រមោចខ្ទួនតូច ៗ ពេកសល់
យកទុកប្រើការដល់គ្រាក្រ ។

ចំ ៗ ជាន់ខ្ទួនបីបួនណា
ស្រមោចគុះកុំគ្នាឈ្មួនរ

បើពាំពុំរួចអាហារធំ
ទទួលអំណរពាំចំណី ។

នាំគ្នាម៉ូមារត់ស្រុះស្រេ
រៀនគាក់ព្រោះពុំយល់សេចក្ដី

ដូចពួកកុលបុត្រឧត្តុង្គសក្តិ
នាំគ្នាឃ្លាតឡិប្រើនវិនិច្ឆ័យ ។

ពាក្យក្នុងគម្ពីរបេទបាលី
ការកពាក្យពិតពាក្យប្រែក

សម្រស់សម្រួលផ្ទៀងពិនិត្យ
យូរទៅគន់យល់ក្តីសន្ទេ

អនុណាទ័យពេញក្ដីថ្លា ។

តូច ៗ ផ្តុំគ្នាកើតជាធំ　　ដូចស្បូវក្រៀញរុំធ្វើខ្សែណា
រឿងនេះខ្ញុំរៀបប្រៀបឧបមា　　សាមគ្គីបណ្ដាកុលបុត្រ　ៗ
ឱស្សាហ៍សង្គ្រោះសន្តោសគ្នា　　ទំនៀមថ្លៃវិសេសសុខ
ព្យាយាមតាំងខ្លួនជួនតាំងមុខ　　គ្មានពុតខូចចិលខ្ជិលក្នុងកាយ　ៗ
ប្រទះគម្រិះឧត្តមល្អ　　ចេះតែកបន្តបន្តក់ផ្សាយ
ដូចមេមាន់ល្អប្រឹងកកាយ　　បានបាយចំតែកចែកកូនស៊ី　ៗ
មិនចេះកំណាញ់ស្ងួតជាតិ　　បានហើយរៀបទៀតលាក់ទៅ
មិនគិតឲ្យកើតផលសំគី　　ដូចដីគ្មានជីតាក្រក់សល់　ៗ
កំណាញ់កើតពីខ្ជិលធ្វើទាន　　ជាទីប្រមាណនាំផ្ដាច់ផ្ដល់
កុំឲ្យយល់យន់នៃកុសល　　ដូចខ្វាក់ពុំយល់ស្គាល់លោក　ៗ
បើខ្លួនកំណាញ់លាក់គម្រិះ　　មិនឲ្យគេចេះពីគ្នា
គម្រិះគម្រោយអន្តរាយ　　ខ្លួនស្លាប់កាលណាឥតសាបាក់　ៗ
ត្រូវយកគម្រោចព្រះសម្ពុទ្ធ　　ជាគ្រូវិសុទ្ធលើបរិស័ទ
ឃើញធម៌ល្អ ៗ ចរក្កាត់　　ទេសនាប្រាប់សត្វគ្រប់ ៗ គ្នា　ៗ
ព្រះទ័យមេត្តាសត្វខ្ញុំទៅ　　កុំថែលស្ងៀមនៅ ១ វេលា
ប្រដៅឲ្យចំរៀនធម្មា　　បច្ច័យស្មារតិគ្មាននាយ　ៗ
　　ខ្ញុំប្រែកតីកាសផ:　　កុំទាន់អស់លក្ខណៈទូលាយ
ឲ្យក្ដីល្អល្អះច្បាស់ពណ្ណរាយ　　សូមជនសម្លាយអត់ទោសា　ៗ

រឿងនេះខ្ញុំតែងតាមគំនិត គំនិតកើតនឹងចិនបញ្ញា

តាមទំនងពងពិតផងឧបមា សូមតាមមេត្តាកុំនិន្ទា ។

អ្នកមើលពិរោះអស់ពាក្យនេះ បើល្អសូមរិះគុណទ័យា

កុំឲ្យបាបធម៌កោសជា មកធ្វើជាមារពោធាបាន ។

បើលះខ្ញុំលរួចបួចចំណាន នេះពេញជាប្បីជនសព្វហាន

ដូចជាទន់ជ័យអម្យាលមាណ លោកសិនកប់តាមហៅជាល្អ ។

មានកេរ្តិ៍មានឈ្មោះមានយសសក្តិ មានមាសមានប្រាក់ខ្ញុំកំដរ

ញុំាងភូជញុំាងពន្សវង្សបវរ ញុំាងឲ្យនគរមានវុឌ្ឍា ។

ញុំាងសាសន៍ព្រះពុទ្ធឲ្យប្រពៃ ញុំាងធម៌វិន័យនិងសង្ឃា

សរត្ថាសព្រោសសត្វកាត់វេក ទុកជាចំណាតទៅតើយ ។

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ
ស្កេនជា eBook ដោយ អ៊ុន ជុន
វិច្ឆិកា ឆ្នាំ ២០១៦
គាំទ្រដោយលោក ស្រ៊ុន តាំងហ៊ាង និងលោកស្រី អ៊ឹង ស៊ុយហ៊ួរ

សូមអរគុណ
ខ្ញៅ យុនសំរ៉ង
ប្រធាន
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE